អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
អគ្គនាយកដ្ឋានស្រាវជ្រាវ
នាយកដ្ឋានស្រាវជ្រាវថវិកា

# ព្រឹត្តិបត្រព័ត៌មានថវិកា និងសេដ្ឋកិច្ច

**មាតិកា៖**

- ក្រុមប្រឹក្សាធុរកិច្ច អាមេរិក-អាស៊ាន មានបំណងវិនិយោគ លើវិស័យចំនួន៦ នៅកម្ពុជា
- កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-កូរ៉េនឹងចុះហត្ថលេខានៅថ្ងៃទី២៦ តុលាឆ្នាំ២០២១
- ADBផ្តល់កម្ចី៥០លានដុល្លារដល់កម្ពុជាអភិវឌ្ឍវិស័យហិរញ្ញវត្ថុ
- ការនាំចេញផលិតផលកាត់ដេររបស់ប្រទេសកម្ពុជាបន្តកើនជាង១១%បើទោះបីជាមានការរីករាលដាលជំងឺកូវីដ-១៩ ដែលរំខានដល់ការផលិតក៏ដោយ
- កម្ពុជានៅតែពឹងផ្អែកទីផ្សារវៀតណាមខ្លាំង សម្រាប់ការនាំចេញផលិតផលកសិកម្ម
- តើវិស័យអគ្គិសនីកម្ពុជាទទួលរងឥទ្ធិពលអ្វីខ្លះពីបញ្ហាកង្វះថាមពលធ្ងន់ធ្ងររបស់សកលលោក?
- តម្លៃប្រេងឥន្ធនៈបន្តឡើងថ្លៃ, ក្រសួងពាណិជ្ជកម្មពន្យល់មូលហេតុ និងការជួយអន្តរាគមន៍របស់រដ្ឋ
- ការអនុវត្តថវិការបស់ប្រទេសហ្វីលីពីនរយៈពេល៨ខែ ឆ្នាំ២០២១
- សេដ្ឋកិច្ចឌីជីថលវៀតណាម នឹងអាចបង្កើតចំណូល ៧៤ប៊ីលានដុល្លារ ត្រឹមឆ្នាំ២០៣០
- ពាណិជ្ជកម្មឥណ្ឌូនេស៊ីថមថយល្បឿននៅខែកញ្ញា
- ផ.ស.ស របស់ចិនថយចុះ ដោយសារនៅក្នុងត្រីមាសទី៣ មានកំណើនយឺតត្រឹម ៤,៩%
- ភាពច្របូកច្របល់នៃសង្វាក់ផលិតកម្មធ្វើឱ្យប៉ះពាល់ដល់កំណើនសេដ្ឋកិច្ចសកល និងកាន់តែអាក្រក់
- IMF៖កំណើនអតិផរណានិងភាពមិនប្រាកដប្រជាកូវីដ១៩កំពុងគំរាមកំហែងដល់ការស្តារសេដ្ឋកិច្ច


ពិនិត្យ និងកែសម្រួលដោយ

- សួន ពុធថាវី អគ្គនាយិកា នៃអគ្គនាយកដ្ឋានស្រាវជ្រាវ
- គឹម សុចិត្រា អគ្គនាយករង នៃអគ្គនាយកដ្ឋានស្រាវជ្រាវ
- ណុប ចាន់ធី ប្រធាននាយកដ្ឋានស្រាវជ្រាវថវិកា
- ម៉ែន ខែមរៈ អនុប្រធាននាយកដ្ឋានស្រាវជ្រាវថវិកា



រៀបរៀងដោយនាយកដ្ឋានស្រាវជ្រាវថវិកា សប្តាហ៍ទី៤ ខែតុលា ឆ្នាំ២០២១ លេខ ៖ ៩០

## ព័ត៌មាន និងទិន្នន័យអំពីប្រទេសកម្ពុជា

### ក្រុមប្រឹក្សាធុរកិច្ចអាមេរិក-អាស៊ានមានបំណងវិនិយោគលើវិស័យចំនួន៦ នៅកម្ពុជា




*ប្រភព ៖ ដើមអម្ពិល*

ក្រុមប្រឹក្សាធុរកិច្ចអាមេរិក-អាស៊ាន មានបំណងចង់វិនិយោគនៅកម្ពុជា លើវិស័យថាមពល វិស័យឧស្សាហកម្ម វិស័យសុខាភិបាល វិស័យបច្ចេកវិទ្យា វិស័យហិរញ្ញវត្ថុ និងការនាំចេញនាំចូល។ បំណងនេះបានបង្ហាញឡើង ក្នុងឱកាសប្រមុខរាជរដ្ឋាភិបាលកម្ពុជាទទួលជួបពិភាក្សាជាមួយក្រុមប្រឹក្សាធុរកិច្ច អាមេរិក-អាស៊ាន តាមប្រព័ន្ធអនឡាញ នៅព្រឹកថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២១ នេះ។

ប្រមុខរាជរដ្ឋាភិបាលកម្ពុជាបានជម្រាបជូនក្រុមប្រឹក្សាធុរកិច្ចអាមេរិក-អាស៊ាន នូវផែនការចូលរួមដោះស្រាយបញ្ហាបម្រែបម្រួលអាកាសធាតុរបស់កម្ពុជា វិធានការឆ្ពោះទៅមុខរបស់កម្ពុជា ដែលរួមមាន បន្តគ្រប់គ្រងជំងឺកូវីដ១៩ ជំរុញការកែទម្រង់ផ្នែកធុរកិច្ចឱ្យបានកាន់តែប្រសើរ ដើម្បីទាក់ទាញអ្នកវិនិយោគឱ្យបានកាន់តែច្រើន ជំរុញការកែទម្រង់លើគ្រប់វិស័យ និងជំរុញការបង្កើនសកម្មភាពធុរកិច្ច និងលើកទឹកចិត្តឱ្យវិស័យឯកជនចូលរួម ដើម្បីជំរុញសេដ្ឋកិច្ចកម្ពុជា។

ប្រមុខរាជរដ្ឋាភិបាលកម្ពុជាក៏បានជម្រាបជូនដល់ក្រុមប្រឹក្សាធុរកិច្ចអាមេរិក-អាស៊ាន នូវសក្តានុពលអំពីការវិនិយោគនៅក្នុងប្រទេសកម្ពុជា ព្រមជាមួយការអំពាវនាវឱ្យវិនិយោគិនសហរដ្ឋអាមេរិកមកវិនិយោគនៅកម្ពុជានាពេលខាងមុខផងដែរ។ *ដោយ ម៉ែន ខែមរៈ*

*ប្រភព ៖ ដើមអម្ពិល ចេញផ្សាយថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២១។*

### កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-កូរ៉េ នឹងចុះហត្ថលេខានៅថ្ងៃទី២៦ តុលាឆ្នាំ២០២១



*ដោយ ខេមបូណូមីស*

បើគ្មានអ្វីប្រែប្រួលទេ ភាគីទាំងពីរកម្ពុជា-កូរ៉េ នឹងចុះហត្ថលេខាលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីរវាងប្រទេសទាំងពីរនៅថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២១ តាមប្រព័ន្ធអនឡាញ ហើយកិច្ចព្រមព្រៀងនេះ អាចនឹងចូលជាធរមាននៅអំឡុងត្រីមាសទី១ ក្នុងឆ្នាំ២០២២ ព្រោះភាគីទាំងពីរត្រូវចំណាយពេលប្រមាណ៣ខែ ដើម្បីរៀបចំ និងឆ្លងនីតិវិធីផ្ទៃក្នុង។ កិច្ចព្រមព្រៀង

ពាណិជ្ជកម្មសេរីកម្ពុជា-កូរ៉េត្រូវបានភាគីទាំងពីរចុះហត្ថលេខាដើម្បីបិទបញ្ចប់កិច្ចចរចា កាលពីអំឡុងខែកុម្ភៈ ឆ្នាំ២០២១ ដោយកាលនោះការចុះហត្ថលេខាក៏ធ្វើឡើងតាមប្រព័ន្ធអនឡាញដែរ។

កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-កូរ៉េ ក្លាយជាកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទី២ បន្ទាប់ពីកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីរវាងកម្ពុជា-ចិន ដែលគ្រោងចូលជាធរមាននៅដើមឆ្នាំ២០២២។ ក្រៅពីនេះ កម្ពុជាក៏មានកិច្ចព្រមព្រៀងភាពជាដៃគូគ្រប់ជ្រុងជ្រោយថ្នាក់តំបន់ ឬហៅកាត់ថា RCEP និងច្បាប់ស្តីពីការប្រកួតប្រជែងពីរបន្ថែមទៀតផងដែរ ដែលគ្រោងចូលជាធរមាននៅដើមឆ្នាំ២០២២។ ក្រោមកិច្ចព្រមព្រៀង RCEP កម្ពុជានឹងលើកលែងពន្ធប្រមាណ ៩៣,៨% នៃផលិតផលនាំចូលពីកូរ៉េខាងត្បូង ហើយកូរ៉េខាងត្បូងនឹងលើកលែងពន្ធប្រមាណ៩៥,៦% លើផលិផលរបស់កម្ពុជា។

បើតាមរបាយការណ៍របស់ក្រសួងពាណិជ្ជកម្ម ទំហំពាណិជ្ជកម្មទ្វេភាគីកម្ពុជា-កូរ៉េ នៅឆ្នាំ២០២០ សម្រេចបានជិត៩០០លានដុល្លារអាមេរិក ថយចុះប្រមាណ ១៨% បើធៀបនឹងឆ្នាំ២០១៩ ដែលមានជាង១ ០០០លានដុល្លារអាមេរិក។

ទន្ទឹមនឹងនេះ ក្រោមកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ចិន កម្ពុជាអាចនាំចេញទំនិញជាង៣០០មុខទៅកាន់ទីផ្សារចិនដោយមិនចាំបាច់បង់ពន្ធ ដែលវានឹងជួយជំរុញការនាំចេញទំនិញរបស់កម្ពុជាទៅទីផ្សារចិនកើនឡើង២៥%បន្ថែមទៀត។ ពាណិជ្ជកម្មទ្វេភាគីកម្ពុជា-ចិនកាលពីឆ្នាំ២០២០ មានទំហំជាង៨ ០០០លានដុល្លារអាមេរិក ខណៈនៅ៩ខែក្នុងឆ្នាំ២០២១ ទំហំពាណិជ្ជកម្មរវាងប្រទេសទាំងពីរមានជិត៨ ០០០លានដុល្លារអាមេរិក៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព៖ខេមបូឌាមីស ចេញផ្សាយថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២១។*

## ADBផ្តល់កម្ចី៤០លានដុល្លារដល់កម្ពុជាអភិវឌ្ឍវិស័យហិរញ្ញវត្ថុ




*ដោយ ខេមបូឌាមីស*

ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) បានអនុម័តប្រាក់កម្ចីចំនួន ៤០លានដុល្លារ ដើម្បីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែង របស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការពង្រីកលទ្ធភាពទទួលបានឥណទាន ក្នុងចំណោមសហគ្រាសធុនតូច និងមធ្យម (SMEs) និងអនុវត្តកំណែទម្រង់ ដើម្បីជំរុញស្ថិរភាពហិរញ្ញវត្ថុ និងធ្វើឱ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធវិស័យហិរញ្ញវត្ថុ។

នេះគឺជាកម្មវិធីវគ្គទី៣ នៃកម្មវិធីអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុប្រកបដោយបរិយាប័ន្ន បន្ទាប់ពីកម្មវិធីវគ្គចំនួន២ ពីមុនដែលត្រូវបានអនុវត្តកាលពីឆ្នាំ ២០១៦ ដល់ឆ្នាំ ២០១៩ ដើម្បីជួយកម្ពុជា អភិវឌ្ឍវិស័យហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធភាព និងស្ថិរភាព តាមរយៈការជំរុញបរិយាប័ន្នហិរញ្ញវត្ថុ និងស្ថិរភាពហិរញ្ញវត្ថុ។

អ្នកឯកទេសផ្នែកហិរញ្ញវត្ថុ របស់ធនាគារអភិវឌ្ឍន៍អាស៊ី បានលើកឡើងថា រាជរដ្ឋាភិបាលកម្ពុជា បានបោះជំហានយ៉ាងសំខាន់ ក្នុងការរក្សាស្ថិរភាពហិរញ្ញវត្ថុ និងធ្វើឱ្យការគ្រប់គ្រងវិបត្តិមានភាពប្រសើរឡើង ក្នុងពេលមានជំងឺរាតត្បាតកូវីដ-១៩។ តាមរយៈកម្មវិធីវគ្គថ្មីនេះ រាជរដ្ឋាភិបាល បានអនុម័តច្បាប់សំខាន់ៗ ដែលគាំទ្រដល់យុទ្ធសាស្ត្របរិយាប័ន្នហិរញ្ញវត្ថុជាតិ និងបានផ្តួចផ្តើមគំនិតជាច្រើន ដើម្បីបង្កើនលទ្ធភាពទទួលបានហិរញ្ញ

វត្ថុ រួមទាំងគម្រោងធានាឥណទានសាធារណៈ សម្រាប់សហគ្រាសធុនតូច និងមធ្យមដំបូងគេនៅកម្ពុជាផងដែរ។ កម្មវិធីរងថ្មីនេះ គាំទ្រកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ជួយសហគ្រាសធុនតូច និងមធ្យម ឱ្យងើបឡើងពីជំងឺរាតត្បាត តាមរយៈការពង្រីកលទ្ធភាពទទួលបានឥណទាន។

កាលពីខែកញ្ញាកន្លងទៅ ធនាគារADBក៏បានចេញរបាយការណ៍ថ្មីមួយរបស់ខ្លួន ដោយបានបន្ទាបការព្យាករកំណើនសេដ្ឋកិច្ចកម្ពុជានៅឆ្នាំ២០២១នេះមក នៅត្រឹម១,៩% ប៉ុណ្ណោះខណៈដែលការព្យាករពីមុនមានដល់ ៤%។ ទោះយ៉ាងណា តាមការព្យាករពីធនាគារ ADB ដដែលនេះ សម្រាប់ឆ្នាំ២០២២ សេដ្ឋកិច្ចកម្ពុជានឹងមានការងើបឡើងវិញនៅកម្រិត៥,៥%៕

*ដោយ ម៉ែន ខែមរៈ*

*ប្រភព៖ខេមបូណ្ឌមីសចេញផ្សាយថ្ងៃទី១៩ខែតុលា ឆ្នាំ២០២១។*

## ការនាំចេញផលិតផលកាត់ដេររបស់ប្រទេសកម្ពុជាបន្តកើនជាង១១%បើទោះបីជាមានការរីករាលដាលជំងឺកូវីដ-១៩ដែលរំខានដល់ការផលិតក៏ដោយ



*ប្រភព៖postkhmer, ២០២១ រូបភាព៖ ម៉ៃ គុណមករា*

យោងតាមទិន្នន័យ ដែលបង្ហាញដោយអគ្គនាយកដ្ឋានគយ និងរដ្ឋាកររបស់ប្រទេសកម្ពុជាបានបញ្ជាក់ថា៖ គិតត្រឹមរយៈពេល៩ខែនៃឆ្នាំ២០២១ ការនាំចេញផលិតផលកាត់ដេរពីប្រទេសកម្ពុជាសម្រេចបានតម្លៃសរុបជាង ៨,២ ប៊ីលានដុល្លារ កើនឡើងជាង ១១% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំ ២០២០ បើទោះបីជាមានការរីករាលដាលជំងឺកូវីដ-១៩ ជាពិសេសការផ្ទុះនៅក្នុងសហគមន៍ និងមានការបិទខ្ទប់តំបន់ខ្លះរយៈពេលខ្លីកន្លងមក ដែលបានរំខានដល់ខ្សែសង្វាក់ផលិតកម្មក៏ដោយ។

អគ្គលេខាធិការសមាគមរោងចក្រកាត់ដេរនៅកម្ពុជា (GMAC)លោក ខេន លូ បានលើកឡើងថា ទោះបីក្នុងអំឡុងពេលនៃការរីករាលដាលជំងឺកូវីដ-១៩ ក៏ការបញ្ជាទិញផលិតផលកាត់ដេរមិនបានធ្លាក់ចុះនោះទេ ពិសេសការទទួលបានចំណែកទីផ្សារពីប្រទេសផលិតមួយចំនួនដែលកំពុងជួបបញ្ហាដោយសារបញ្ហានយោបាយ និងផលប៉ះពាល់ពីជំងឺកូវីដ-១៩។ ជាក់ស្តែងឆ្នាំនេះប្រទេសកម្ពុជាមានសំណាងដោយទទួលបានការបញ្ជាទិញមួយចំនួនពីប្រទេសមីយ៉ាន់ម៉ា។

ស្របពេលជាមួយគ្នានេះដែរ អ្នកស្រាវជ្រាវសេដ្ឋកិច្ចអន្តរជាតិនៃវិទ្យាស្ថានទំនាក់ទំនងអន្តរជាតិនៃកម្ពុជាបានលើកឡើងថា កំណើនការនាំចេញផលិតផលកាត់ដេរសម្លៀកបំពាក់បង្ហាញពីសញ្ញាវិជ្ជមាននៃសកម្មភាពសេដ្ឋកិច្ចកម្ពុជា ខណៈប្រទេសដទៃទៀតកំពុងរងផលប៉ះពាល់យ៉ាងខ្លាំងពីការរីករាលដាលនៃជំងឺកូវីដ- ១៩។ ប្រទេសកម្ពុជានៅតែជាទីកន្លែងវិនិយោគដ៏ទាក់ទាញនៅក្នុងតំបន់ ដោយសារតែរដ្ឋាភិបាលកំពុងធ្វើការកែទម្រង់សេដ្ឋកិច្ច ដូចជាបើកទីផ្សារថ្មីៗក្នុងតំបន់តាមរយៈការចុះកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគី និងពហុភាគី ការដាក់ចេញនូវច្បាប់វិនិយោគថ្មី និងការចុះបញ្ជីតាមប្រព័ន្ធអេឡិចត្រូនិក ដែលក៏កំពុងដើរតួយ៉ាងសំខាន់ក្នុងការទាក់ទាញអ្នកវិនិយោគ និងការសម្រួលពាណិជ្ជកម្មនានា។

បន្ថែមពីនេះ រាជរដ្ឋាភិបាលកំពុងខំសម្រួលបរិយាកាសវិនិយោគ និងធុរកិច្ចក្នុងស្រុក ដើម្បីធ្វើយ៉ាងណាផ្តល់ឱ្យ

ធុរជន និងអ្នកវិនិយោគនូវទំនុកចិត្ត ស្របពេលដែលការបើកទីផ្សារថ្មីៗ ជាពិសេសពាណិជ្ជកម្មសេរីជាមួយចិន កូរ៉េខាងត្បូង និងប្រទេសផ្សេងៗទៀតនឹងរឹតតែធ្វើឱ្យកម្ពុជាក្លាយជាទិសដៅវិនិយោគដ៏ល្អ៕ *ដោយ សេន ចន្ទូ*

*ប្រភព៖ Postkhmer, ចេញផ្សាយថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២១*

## កម្ពុជានៅតែពឹងផ្អែកទីផ្សារវៀតណាមខ្លាំង សម្រាប់ការនាំចេញផលិតផលកសិកម្ម



*ដោយ ខេមបូឌាមីស*

ប្រទេសវៀតណាមជាទិសដៅសំខាន់បំផុតនៃការនាំចេញកសិផលកម្ពុជា។ រយៈពេល៩ខែឆ្នាំ២០២១កម្ពុជាបាននាំចេញកសិផលជិត ៦លានតោន ទៅកាន់ទីផ្សារអន្តរជាតិ។ ក្នុងនោះកសិផលសរុប ជាង៦៤% ដែលកម្ពុជាបាននាំចេញទៅប្រទេសវៀតណាម។

ក្នុងនោះកម្ពុជាក៏នាំចេញកសិផលទៅកាន់ប្រទេសថៃប្រមាណ២០% និង ប្រទេសចិន ជិត១០% ផងដែរ។ បើទោះបីកម្ពុជាបាននិងកំពុងជួបនូវវិបត្តិកូវីដ-១៩ តែសន្ទុះនៃការនាំចេញផលិតផល មិនមានការថមថយនោះទេ។ តើមានកត្តាសំខាន់អ្វីខ្លះ ដែលធ្វើឱ្យកម្ពុជាបន្តពឹងផ្អែកលើទីផ្សារវៀតណាម ក្នុងការនាំចេញកសិផល?

ប្រធានក្រុមប្រឹក្សាភិបាលសហព័ន្ធស្រូវ-អង្ករកម្ពុជា និងជាអ្នកជំនួញក្នុងវិស័យកសិកម្ម បានគូសបញ្ជាក់ថា តាំងពីកម្ពុជាជួបនូវគ្រោះមហន្តរាយកូវីដ-១៩ ការនាំចេញកសិផលទៅកាន់ទីផ្សារក៏បានជួបបញ្ហាមួយចំនួនដែរ ពិសេសនៅប៉ែកអឺរ៉ុប ព្រោះកង្វះបញ្ហាដឹកជញ្ជូន។ ការណ៍នេះក៏បានធ្វើឱ្យកម្ពុជាកាន់តែងាកទៅរកទីផ្សារក្នុងតំបន់ ពិសេសប្រទេសវៀតណាម ដែលមានតម្រូវការខ្ពស់នូវកសិកម្មផលសម្រាប់កែច្នៃ។ ហើយការនាំចេញទៅប្រទេសវៀតណាម មានភាពងាយស្រួល និងមិនចាំបាច់ចំណាយពេលយូរ។

រាជរដ្ឋាភិបាលកម្ពុជាបានបើកទូលាយនូវការនាំចេញកសិផលមិនទាន់កែច្នៃ ទើបធ្វើឱ្យឈ្មួញពីប្រទេសវៀតណាមមានភាពងាយស្រួល ក្នុងការប្រមូលទិញ និងដឹកជញ្ជូនកសិផលពីកម្ពុជា។ សម្រាប់ថ្លៃដឹកជញ្ជូន ក៏ចំណាយតិចផងដែរ ដែលធ្វើឱ្យលំហូរកសិផលទៅប្រទេសវៀតណាម មានចំនួនច្រើន ជាងទីផ្សារប្រទេសដទៃ។

អ្នកជំនាញយល់ថា កម្ពុជាមិនត្រូវពឹងផ្អែកទាំងស្រុងលើវៀតណាមនោះទេ ព្រោះតម្លៃនៃការចេញទៅវៀតណាម ហាក់នៅមានកម្រិតនៅឡើយ។ ដូច្នេះ ទាមទារឱ្យកម្ពុជាបន្តពង្រឹងបន្ថែមនូវគុណភាព លទ្ធភាព និងសមត្ថភាព ក្នុងខ្សែសង្វាក់ផលិតកម្ម ដើម្បីផ្គត់ផ្គង់កសិផលលើទីផ្សារ។

រយៈពេល ៩ខែ ក្នុងឆ្នាំ២០២១ នេះ កម្ពុជាបាននាំចេញកសិផលជិត ៦លានតោន ទៅកាន់ទីផ្សារអន្តរជាតិ ដែលគិតជាទឹកប្រាក់មានជាង ៣ពាន់លានដុល្លារអាមេរិក បានកើនឡើងជាង៨៨% បើប្រៀបនឹងរយៈពេលដូចគ្នា កាលពីឆ្នាំ២០២០៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព៖ខេមបូឌាមីស ចេញផ្សាយថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២១។*

## តើវិស័យអគ្គិសនីកម្ពុជាទទួលរងឥទ្ធិពលអ្វីខ្លះពីបញ្ហាកង្វះថាមពលធ្ងន់ធ្ងររបស់សកលលោក?



*ដោយ ខេមបូណ្ឌមីស*

បញ្ហាតម្លៃប្រេងឥន្ធនៈកំពុងឡើងថ្លៃ និងកង្វះថាមពលប្រើប្រាស់ជាសកល បានជះឥទ្ធិពលដល់ការផលិតថាមពលអគ្គិសនីនៅកម្ពុជា ប៉ុន្តែមិនបានធ្វើឱ្យកម្ពុជាខ្វះថាមពលអគ្គិសនីសម្រាប់ប្រើប្រាស់ដូចប្រទេសធំៗមួយចំនួននោះទេ គ្រាន់តែមានការកើនឡើងថ្លៃដើមនៃការផលិតប៉ុណ្ណោះ។ ទោះបីថ្លៃដើមផលិតអគ្គិសនីនៅកម្ពុជាបច្ចុប្បន្នមានការឡើងថ្លៃក៏ដោយ ក៏មិនដំឡើងថ្លៃអគ្គិសនីដែរ។ បច្ចុប្បន្នកម្ពុជាមានថាមពលអគ្គិសនីគ្រប់គ្រាន់ក្នុងការផ្គត់ផ្គង់តម្រូវការប្រើប្រាស់សម្រាប់ប្រជាពលរដ្ឋ ក៏ដូចជាក្រុមហ៊ុន រោងចក្រ សហគ្រាស និង អាជីវកម្មផ្សេងៗ។

រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាអគ្គនាយកអគ្គិសនីកម្ពុជាបានបញ្ជាក់ថា តម្លៃប្រេងឥន្ធនៈ និងធ្យូងថ្មឡើងថ្លៃ ដែលបង្កជាវិបត្តិថាមពលសកល បានជះឥទ្ធិពលខ្លះដែរ មកវិស័យថាមពលអគ្គិសនីកម្ពុជា គឺបានធ្វើឲ្យថ្លៃដើមផលិតអគ្គិសនីរបស់រោងចក្រដើរដោយប្រេងឥន្ធនៈ និងធ្យូងថ្មនៅកម្ពុជាមានការកើនឡើងមួយកម្រិត។ នៅឆ្នាំ២០២១ កម្ពុជាបានបន្ថែមស្ថានីយអគ្គិសនីដើរដោយពន្លឺព្រះអាទិត្យទំហំ ១២០មេហ្កាវ៉ាត់ ដើម្បីជួយបំពេញតម្រូវការប្រើប្រាស់ក្នុងស្រុក។

គួររំលឹកថា ប្រទេសធំៗមួយចំនួននៅលើពិភពលោក និងក្នុងតំបន់បាននិងកំពុងប្រឈមនឹងកង្វះខាតថាមពលសម្រាប់ប្រើប្រាស់លើតម្រូវការប្រចាំថ្ងៃ និងអាជីវកម្ម។ វិបត្តិថាមពលនេះ បានកើតឡើងក្រោយតម្រូវការប្រើប្រាស់ថាមពលអគ្គិសនីលើសកលលោកមានការកើនឡើង បន្ទាប់ការស្ទុះងើបឡើងវិញនៃសេដ្ឋកិច្ចរបស់ប្រទេសទាំងនោះ គួបផ្សំការកាត់បន្ថយការប្រើប្រាស់ធ្យូងថ្មក្នុងការផលិតថាមពលអគ្គិសនី និងតម្លៃប្រេងឥន្ធនៈឡើងថ្លៃជាដើម៕ *ដោយ ម៉ែន ខែមរៈ* *ប្រភព៖ខេមបូណ្ឌមីស ចេញផ្សាយថ្ងៃទី១៦ ខែតុលា ឆ្នាំ២០២១។*

## តម្លៃប្រេងឥន្ធនៈបន្តឡើងថ្លៃ, ក្រសួងពាណិជ្ជកម្មពន្យល់មូលហេតុ និងការជួយអន្តរាគមន៍របស់រដ្ឋ




*ប្រភព ៖ freshnews*

តម្លៃប្រេងឥន្ធនៈលក់រាយតាមស្ថានីយមានការកើនថ្លៃជាបន្តបន្ទាប់បានធ្វើឱ្យប្រជាពលរដ្ឋមានការអ៊ូរទាំ ដោយការឡើងថ្លៃនេះធ្វើឱ្យប៉ះពាល់ដល់ជីវភាពពួកគេ។ អ្នកនាំពាក្យក្រសួងពាណិជ្ជកម្មប្រាប់ឱ្យដឹងថា ការកើនឡើងនេះអាស្រ័យទៅលើតម្លៃប្រេងរបស់ទីផ្សារអន្តរជាតិ ការកើនឡើងនេះមិនមែនជាចេតនា និងមិនមែនជាអ្វី ដែលរាជរដ្ឋាភិបាលកំណត់នោះទេ វាជាឥទ្ធិពលតម្រូវការ និងការផ្គត់ផ្គង់។ កម្ពុជាមិនមែនជាប្រទេសផលិតប្រេង ហើយកម្ពុជាទិញប្រេងពីសិង្ហបុរី និងនាំចូលប្រេងពីប្រទេសជិតខាង ដូច្នេះនៅពេលដែលថ្លៃ

ប្រេងអន្តរជាតិស្ទុះឡើង វាធ្វើឱ្យជះឥទ្ធិពល ដល់ការលក់រាយថ្លៃប្រេងឥន្ទនៈរបស់កម្ពុជា។ រាជរដ្ឋាភិបាលបានធ្វើការទប់លំនឹងនៃកំណើននេះ ដោយរក្សាដដែលនូវលើតម្លៃពន្ធ និងការឧបត្ថម្ភធននានា ដោយបន្តឧបត្ថម្ភ ៤សេនដុល្លារក្នុងមួយលីត្រ ដើម្បីធ្វើយ៉ាងណាកុំឱ្យមានការកើនឡើងខ្ពស់ពេក ដែលអាចធ្វើឱ្យប៉ះពាល់ដល់ជីវភាពរបស់ប្រជាពលរដ្ឋ។ មួយរយៈពេលចុងក្រោយនេះ អង្គការ OPEC ដែលជាក្រុមប្រទេសផលិតប្រេងបានព្យាករណ៍ថាតម្រូវការនៅទាប តែឥលូវនេះ តម្រូវការមានការកើនឡើងខ្ពស់ ដូច្នេះតម្លៃប្រេងសកលក៏មានការកើនឡើង។ កម្ពុជានឹងខិតខំរក្សាយ៉ាងណាឱ្យមានស្តុកប្រេងឆ្លើយតបនឹងតម្រូវការ ឱ្យប្រជាពលរដ្ឋមានលទ្ធភាពប្រើប្រាស់ ដើម្បីបម្រើជីវភាពប្រចាំថ្ងៃ។

តម្រូវការប្រេងមានការកើនឡើង ដោយសារតែមានបើកការធ្វើដំណើរឡើងវិញ តាមបណ្តាប្រទេសនីមួយៗ។ ជាក់ស្តែងដូចជា កម្ពុជាជាប្រទេសនៅក្នុងតំបន់អភិវឌ្ឍន៍មានរោងចក្រ សហគ្រាស នៅតែបើកដំណើរការ។

កិច្ចសន្យាជួញដូរនាពេលអនាគតសម្រាប់ប្រេងឆៅប្រភេទ Brent របស់អង់គ្លេស បានឡើងថ្លៃ១%ក្នុងមួយបារ៉ែល។ កិច្ចសន្យាជួញដូរនាពេលអនាគតសម្រាប់ប្រេងឆៅប្រភេទ West Texas Intermediate (WTI) របស់អាមេរិក បានឡើងថ្លៃ១,៤%ក្នុងមួយបារ៉ែល។ កិច្ចសន្យាជួញដូរប្រេងឆៅទាំងពីរនេះ បានឡើងថ្លៃយ៉ាងហោចណាស់ ៣%កាលពីសប្តាហ៍មុន៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព ៖ freshnews ចេញផ្សាយថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២១។*

## តារាងប្រចាំសប្តាហ៍

### តារាងទី១៖ ចំណែកទីផ្សារអន្តរជាតិសម្រាប់ទំនិញនាំចេញកម្ពុជាក្នុងរយៈពេល៨ខែ ឆ្នាំ២០២១

តាមទិន្នន័យរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុកម្ពុជាបង្ហាញថា ក្នុងរយៈពេល៨ខែឆ្នាំ២០២១ ការនាំចេញទំនិញកម្ពុជាទៅកាន់ទីផ្សារអាមេរិកមានចំណែកទីផ្សារដល់ ៤២,៦% នៃការនាំចេញសរុប និងតាមពីក្រោយដោយសហគមន៍អឺរ៉ុប ដែលមានចំណែកទីផ្សារប្រមាណជា ១៨,៥%នៃការនាំចេញសរុបរបស់កម្ពុជា។
ចំណែកការនាំចេញទំនិញកម្ពុជាទៅកាន់ប្រទេសសចិនមានចំណែកទីផ្សារប្រមាណជា ៨,៨% ជប៉ុនមាន៦,៥% បណ្តាប្រទេសអាស៊ានមានចំណែកទីផ្សារប្រមាណជា ៦,៥% និង អង់គ្លេសមាន៤% ។
ដោយឡែក ការនាំចេញទៅកាន់បណ្តាប្រទេសផ្សេងៗមានចំណែកទីផ្សារនាំចេញរហូតដល់ ១៣,២% នៃការនាំចេញសរុប៕ *ដោយ មិត្ត ចន្ទី*




*ប្រភព៖និន្នាការសេដ្ឋកិច្ចសង្គម៖ របាយការណ៍ប្រចាំខែសីហា ឆ្នាំ២០២១*

### តារាងទី២៖ កំណើននៃការនាំចេញទំនិញ (ដកមាសចេញ) រយៈពេល៨ខែដំបូង ក្នុងឆ្នាំ២០២១

តាមទិន្នន័យរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុកម្ពុជា បង្ហាញថា នៅក្នុងរយៈពេល៨ខែដំបូងឆ្នាំ២០២១នេះ ការនាំចេញទំនិញ(ដកមាសចេញ)របស់ប្រទេសកម្ពុជា មានទំហំទឹកប្រាក់សរុបប្រមាណជា ១១ ០១០លានដុល្លារ ដែលមានកំណើន ២០,៤% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន។

ជាក់ស្តែង ការនាំចេញទំនិញវាយនភ័ណ្ឌ មានការកើនឡើងប្រមាណជា ៨,២% ធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន។ ទន្ទឹមនឹងនោះដែរ នៅក្នុងរយៈពេល៨ខែឆ្នាំ២០២១នេះ ការនាំចេញកង់មានកំណើនប្រមាណជា ២៤,៦% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំមុន។ ដោយឡែក ការនាំចេញទំនិញផ្សេងៗ មានការកើនឡើងខ្លាំងប្រមាណជា ៦៣,៦% ធៀបនឹងរយៈពេល៨ខែដំបូងដូចគ្នាកាលពីឆ្នាំមុន។

ក៏ប៉ុន្តែ ការនាំចេញអង្ករមានការធ្លាក់ចុះប្រមាណជា ១៦,៣% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០២០៕

*ដោយ មិត្ត ចន្ទី*




*ប្រភព៖ និន្នាការសេដ្ឋកិច្ចសង្គម៖ របាយការណ៍ប្រចាំខែសីហា ឆ្នាំ២០២១*

## ព័ត៌មាន និងទិន្នន័យរបស់បណ្តាប្រទេសនៅក្នុងអាស៊ាន និងដៃគូពាណិជ្ជកម្មដទៃទៀត

### ការអនុវត្តថវិការបស់ប្រទេសហ្វីលីពីនរយៈពេល៨ខែ ឆ្នាំ២០២១

សម្រាប់រយៈពេល៨ខែដំបូង ឆ្នាំ២០២១ ការអនុវត្តចំណូលថវិកាជាតិសរុបរបស់ប្រទេសហ្វីលីពីនមានចំនួន PHP ២ ០០៥,៧ ប៊ីលាន កើនឡើង ៣,៩% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០២០ ។ ក្នុងនោះចំណូលពន្ធមានចំនួន PHP១ ៨១៣,៩ ប៊ីលាន កើនឡើង ៩,២% ចំណែកឯចំណូលមិនមែនពន្ធ(រួមបញ្ចូលទាំងជំនួយ) មានចំនួន PHP ១៩១ ប៊ីលាន ធ្លាក់ចុះរហូតដល់ ២៨,៩%។ ក្នុងរយៈពេលដូចគ្នានេះ ការប្រមូលចំណូលរបស់ការិយាល័យពន្ធផ្ទៃក្នុងBureau of Internal Revenue (BIR) កើនឡើង៦,៦% ខណៈពេលដែលការប្រមូលចំណូលរបស់ការិយាល័យគយ Bureau of customs(BOC)បានកើនឡើង ១៨,៧% ។

ចំណែកឯ ការចំណាយថវិកាជាតិក្នុងរយៈពេល៨ខែ ឆ្នាំ២០២១ មានចំនួន PHP២ ៩៦៣,៩ប៊ីលាន កើនឡើង ១១% ធៀបនឹងឆ្នាំកន្លងទៅ។ការកើនឡើងនៃចំណាយនេះមួយផ្នែកជួយសង្គ្រោះដល់ប្រជាពលរដ្ឋបាត់បង់ចំណូលក្នុងពេលដែលរដ្ឋាភិបាលដាក់ចេញនូវវិធានការបិទខ្ទប់ និងការដាក់នៅដាច់ដោយឡែក។

សរុបរួមមក ឱនភាពថវិកាជាតិរបស់ប្រទេសហ្វីលីពីនមានការធ្លាក់ចុះនៅក្នុងរយៈពេល៨ខែ ឆ្នាំ២០២១ ចំនួន PHP ៩៥៨,២ ប៊ីលានធៀបនឹងឆ្នាំ២០២០៕

*ដោយ មុំ ចិន្តា*

*ប្រភព៖ នាយកដ្ឋានហិរញ្ញវត្ថុហ្វីលីពីន*

## តារាងប្រៀបធៀបការអនុវត្តថវិការបស់ប្រទេសហ្វីលីពីនក្នុងរយៈពេល៨ខែ(២០១៩-២០២១)

| បរិយាយ | គិតជា ប៊ីលានប៉េសូ (PHP) | | | កំណើន(%) | |
|---|---|---|---|---|---|
| | 2019 | 2020 | 2021 | 2020 | 2021 |
| **ចំណូលសរុប** | **2,091.4** | **1,931.0** | **2,005.7** | **-7.7%** | **3.9%** |
| ចំណូលពន្ធ | 1,879.4 | 1,661.4 | 1,813.9 | -11.6% | 9.2% |
| ការិយាល័យពន្ធផ្ទៃក្នុង | 1,452.3 | 1,303.3 | 1,388.7 | -10.3% | 6.6% |
| ការិយាល័យគយ | 411.2 | 347.3 | 412.3 | -15.6% | 18.7% |
| ការិយាល័យផ្សេងៗ | 15.9 | 10.8 | 12.9 | -31.9% | 19.3% |
| ចំណូលមិនមែនពន្ធ * | 211.8 | 269.4 | 191.5 | 27.2% | -28.9% |
| **ចំណាយ** | **2,211.8** | **2,671.2** | **2,963.9** | **20.8%** | **11.0%** |
| **តុល្យភាព** | **-120.4** | **-740.2** | **-958.2** | **514.6** | **29.5** |

**បូកបញ្ចូលទាំងជំនួយ ប្រភព៖ Bureau of The Treasury*

## សេដ្ឋកិច្ចឌីជីថលវៀតណាម នឹងអាចបង្កើតចំណូល ៧៤ប៊ីលានដុល្លារ ត្រឹមឆ្នាំ២០៣០




*ប្រភព៖ Vietnam Plus, រូបភាព៖ VNA*

កាលពីពេលថ្មីៗនេះ នៅក្នុងសិក្ខាសាលា ដែលរៀបចំឡើងដោយមជ្ឈមណ្ឌលនិវានុវត្តជាតិវៀតណាម នៃក្រសួងផែនការនិងវិនិយោគ និង Google បានបង្ហាញថា ក្នុងករណី វៀតណាមប្រើប្រាស់បច្ចេកវិទ្យាឌីជីថលដល់កម្រិតអតិបរមា នោះនឹងអាចបង្កើតចំណូល ដែលត្រូវប៉ាន់ស្មានប្រមាណជា ១ ៧៣៣ទ្រីលានដុង ឬស្មើនឹង ៧៤ប៊ីលានដុល្លារអាមេរិក ដល់សេដ្ឋកិច្ចត្រឹមឆ្នាំ ២០៣០ ជាពិសេស វិស័យកម្មន្តសាល វិស័យកសិកម្ម និងម្ហូបអាហារ និងវិស័យអប់រំ-បណ្តុះបណ្តាល។ គួរបញ្ជាក់ថា សិក្ខាសាលានេះមានគោលបំណងក្នុងការត្រួតពិនិត្យស្ថានភាពបច្ចុប្បន្ន ការអភិវឌ្ឍសេដ្ឋកិច្ចឌីជី-ថល យន្តការនិងគោលនយោបាយជំរុញកំណើនសេដ្ឋ-កិច្ចឌីជីថល។ រីឯព័ត៌មាន និងទិន្នន័យដែលត្រូវបានប្រើប្រាស់ក្នុងសិក្ខាសាលានេះ ផ្អែកលើរបាយការណ៍ស្តីពីសក្តានុពលនៃសេដ្ឋកិច្ចឌីជីថលវៀតណាម ផលិតដោយក្រុមហ៊ុនប្រឹក្សាសេដ្ឋកិច្ចយុទ្ធសាស្ត្រ AlphaBeta។

របាយការណ៍នេះ បានគូសបញ្ជាក់ថា វៀតណាម ជាប្រទេសទី២ នៅក្នុងអាស៊ីអាគ្នេយ៍ ដែលមានសេដ្ឋកិច្ចអ៊ីនធើណិត រីកលូតលាស់លឿន បន្ទាប់ពីឥណ្ឌូនេស៊ី។ ជាក់ស្តែង ប្រជាជនវៀតណាម ដែលមានអាយុក្រោម ៣៥ឆ្នាំ ប្រមាណជា ៧០% គឺជាប្រជាជនវ័យក្មេង មានការអប់រំ និងមានចំណេះដឹងផ្នែកបច្ចេកវិទ្យាទំនើប។ រីឯអត្រាអក្ខរកម្ម ចំពោះប្រជាជនអាយុចន្លោះ ១៥ឆ្នាំ-៣៥ឆ្នាំ មានជាង ៩៨% ខ្ពស់ជាងអត្រាមធ្យមភាពសកល (៩១%) និងប្រជាជនប្រមាណជា ៧០%នៃប្រជាជនសរុប ប្រើប្រាស់ទូរស័ព្ទចល័តទំនើប(Smartphones)។

គួរឱ្យកត់សម្គាល់ផងដែរថា របាយការណ៍នេះ បានគូសបង្ហាញពីឧបសគ្គក្នុងការទាញយកប្រយោជន៍ពីបច្ចេកវិទ្យាឌីជីថល ដែលរួមមាន លក្ខខណ្ឌបទបញ្ញត្តិ ការតភ្ជាប់ឌីជីថល និងកង្វះខាតធនធានមនុស្សដែលមានជំនាញបច្ចេកវិទ្យា៕ *ដោយ **ជា សិរីរតន៍***

*ប្រភព៖ Vietnam Plus ចេញផ្សាយ ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២១*

## ពាណិជ្ជកម្មឥណ្ឌូនេស៊ីថមថយល្បឿននៅខែកញ្ញា



*ប្រភព៖ The Star ២០២១, រូបភាព៖ Jakarta Post/ANN*

យោងតាមទិន្នន័យផ្លូវការរបស់ទីភ្នាក់ងារស្ថិតិឥណ្ឌូនេស៊ី (Statistics Indonesia) បង្ហាញថា កំណើននៃការនាំចេញ និងការនាំចូលនៃប្រទេសឥណ្ឌូនេស៊ីនៅខែកញ្ញា មានការថមថយល្បឿន បន្ទាប់ពីសម្រេចបានកំណត់ត្រាខ្ពស់បំផុតទៅលើការនាំចេញ និងអតិរេកពាណិជ្ជកម្មនៅខែកក្កដា។

ការនាំចេញសរុបនៅខែកញ្ញានេះ មានទំហំប្រមាណជា ២០,៦០ប៊ីលានដុល្លារ កើនឡើងប្រមាណជា ៤៧,៦៤% បើធៀបនឹងខែកញ្ញា ឆ្នាំ២០២០ តែទាបជាងការនាំចេញនៅខែសីហា ដែលមានអត្រាកំណើន ៦៤,១%។ សម្រាប់ការនាំចូលវិញ មានទំហំ ១៦,២៣ប៊ីលានដុល្លារ កើនឡើង ៤០,៣១%បើធៀបនឹងរយៈពេលដូចគ្នា នៅឆ្នាំមុន និងទាបកំណើនការនាំចេញខែមុន ដែលមានអត្រា ៥៥,២៦%។ ជាលទ្ធផល អតិរេកពាណិជ្ជកម្មខែកញ្ញា មានទំហំសរុប ៤,៣៧ប៊ីលានដុល្លារ ធ្លាក់ចុះ ៨% បើធៀបនឹងទំហំអតិរេកខែសីហា។

គួរបញ្ជាក់ផងដែរថា ការនាំចេញសរុប(លើកលែងប្រេងឥន្ធនៈ និងហ្គាស)សម្រាប់ខែកញ្ញា ធ្លាក់ចុះ ៣,៣៨% បើធៀបនឹងខែសីហា ដោយសារតែការធ្លាក់ចុះនៃតម្រូវការទំនិញពីដៃគូពាណិជ្ជកម្ម ជាជាងការធ្លាក់ចុះនៃតម្លៃទំនិញ។ ចំណែកឯ ការនាំចូលសរុបខែកញ្ញាវិញ បានធ្លាក់ចុះ ២,៦៧% បើធៀបនឹងខែមុន។ គួរឱ្យកត់សម្គាល់ដែរថា អតិរេកពាណិជ្ជកម្មសរុបសម្រាប់រយៈពេល៩ខែ មានទំហំ ២៥,០៧ប៊ីលានដុល្លារ ខ្ពស់ជាងជិត ២ដង នៃទំហំអតិរេកពាណិជ្ជកម្ម សម្រាប់រយៈពេលដូចគ្នា ឆ្នាំ២០២០(១៣,៣៥ប៊ីលានដុល្លារ)។ *ដោយ **ជា សិរីរតន៍***

*ប្រភព៖ TheStar ចេញផ្សាយ ថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២១*

## សេដ្ឋកិច្ចសកល

### ផ.ស.ស របស់ចិនថយចុះ ដោយសារនៅក្នុងត្រីមាសទី៣ មានកំណើនយឺតត្រឹម ៤,៩%



*រូបថតដោយ៖ Wang Jianmin/Visual China Group/ Getty Images*

យោងតាមសម្ដីរបស់អ្នកនាំពាក្យការិយាល័យស្ថិតិជាតិរបស់ចិនបានឱ្យដឹងថា ចាប់តាំងពីត្រីមាសទី៣មក ហានិភ័យ និងកត្តាប្រឈមនៅក្នុងសាកលលោកមានការកើនឡើងបានធ្វើឱ្យកំណើន ផ.ស.ស របស់ចិនទាបជាងការរំពឹងទុក ៥,២% នេះបើយោងតាមការអង្កេតរបស់ Reuters ដែលធ្វើឡើងជាមួយអ្នកវិភាគនានា ពោលសេដ្ឋកិច្ចចិនកើនឡើងត្រឹមតែ ៤,៩% ប៉ុណ្ណោះ នៅក្នុងត្រីមាសទី៣ បើធៀបទៅនឹងឆ្នាំមុន។ នៅក្នុងខែកញ្ញា កំណើនរបស់វិស័យឧស្សាហកម្មនៅចិនកើនឡើងក្នុងអត្រា ៣,១% ទាបជាងការព្យាករណ៍ដែលបានរំពឹងថានឹងអាចកើនឡើងដល់ ៤,៥%។

កំណើនយឺតនេះបណ្ដាលមកពីកង្វះថាមពល ដែលនាំឱ្យមានផលប៉ះពាល់ ដល់ផលិតកម្មរបស់ចិន។ ជាក់ស្ដែង រោងចក្រមួយចំនួនផ្អាកការផលិតកាលពីចុងខែកញ្ញា

ដោយសារតម្លៃធ្យូងថ្មនៅប្រទេសចិនកើនឡើង និងដោយសារតែកង្វះអគ្គិសនីបានធ្វើឱ្យអាជ្ញានៅតាមមូលដ្ឋានកាត់បន្ថយការប្រើប្រាស់ថាមពល។ ទោះយ៉ាងណាចិនបានអះអាងថា ផលប៉ះពាល់ចំពោះសេដ្ឋកិច្ចនេះអាចគ្រប់គ្រងបាន។ រដ្ឋាភិបាលថ្នាក់ជាតិបានបង្ហាញការប្តេជ្ញាចិត្តថា នឹងបង្កើនការផ្គត់ផ្គង់ធ្យូងថ្ម និងធានាដល់ការផ្គត់ផ្គង់អគ្គិសនី។

កត្តាមួយទៀតនោះគឺ ការវិនិយោគលើទ្រព្យសកម្មថេរនៅក្នុងអំលុងបីត្រីមាសដំបូងនៅចិនឆ្នាំនេះមានភាពទន់ខ្សោយជាងការរំពឹងទុក គឺមានកំណើនត្រឹមតែ ៧,៣% បើធៀបទៅនឹងឆ្នាំមុនទាបជាងការរំពឹងទុក ៧,៩%។ ការធ្លាក់ចុះលើការវិនិយោគនេះដោយសារតែប្រទេសចិនចាប់ផ្តើមរឹតបន្តឹងលើលក្ខខណ្ឌនៃការផ្តល់ប្រាក់កម្ចី។ កត្តានេះបានធ្វើឱ្យការវិនិយោគលើទ្រព្យសកម្មថេរធ្លាក់ចុះចំនួន ២,៥% នៅក្នុងខែកញ្ញា បើធៀបនឹងឆ្នាំទៅ ដែលការធ្លាក់ចុះនេះត្រូវបានទាញទម្លាក់ដោយសារការធ្លាក់ចុះលើការវិនិយោគផ្នែកអចលនទ្រព្យ ៣,៥%។ គួររំលឹកថា វិស័យអចលនទ្រព្យ និងវិស័យឧស្សាហកម្មដែលពាក់ព័ន្ធនឹងអចលនទ្រព្យមានទំហំស្មើនឹងមួយភាគបួននៃ ផ.ស.ស របស់ចិន។ ហេតុនេះហើយ ផ.ស.ស របស់ចិននៅក្នុងត្រីមាសទី៣មានកំណើនយឺត ដោយសារតែមានការចូលរួមចំណែកពីវិស័យអចលនទ្រព្យនៅក្នុងសេដ្ឋកិច្ច។

ប៉ុន្តែទោះជាយ៉ាងនេះក្តី ការិយាល័យស្ថិតិជាតិរបស់ចិនបានឱ្យដឹងថា ផលប៉ះពាល់ចំពោះកំណើនសេដ្ឋកិច្ចទាំងមូលនៅមានកម្រិតនៅឡើយ។ ព្រោះការចំណាយរបស់អ្នកប្រើប្រាស់ប្រទេសចិនមានសន្ទុះកើនឡើងផ្ទុយពីស្ថានភាពក្នុងអំលុងពេលដែលរដ្ឋាភិបាលចាត់វិធានការរដ្ឋបាលរឹតបន្តឹងក្នុងអំលុងពេលមានកូវីដ។ ចំណែកឯការលក់រាយនៅប្រទេសចិនក្នុងខែកញ្ញាបានកើនឡើង ៤,៤% ហួសពីការរំពឹងទុក បើធៀបទៅនឹងឆ្នាំមុន៕ *ដោយ វង្ស ច័ន្ទស្មើដារា*

*ប្រភព៖គេហទំព័រCNBCចេញផ្សាយថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២១*

## ភាពច្របូកច្របល់នៃសង្វាក់ផលិតកម្មបានធ្វើឱ្យប៉ះពាល់ដល់កំណើនសេដ្ឋកិច្ចសកល និងកាន់តែអាក្រក់



*រថយន្តដឹកទំនិញចតនៅកំពង់ផែឡូសអេនជីឡេសក្នុងទីក្រុងឡូសអេនជីឡេសរដ្ឋកាលីហ្វ័រញ៉ាសហរដ្ឋអាមេរិក នៅថ្ងៃពុធទី ១៣ ខែតុលាឆ្នាំ ២០២១ ។ រូបថតដោយ៖ BLOOMBERG NEWS*

កំណើននៃការចាក់វ៉ាក់សាំងបានធ្វើឱ្យសេដ្ឋកិច្ចពិភពលោកមានកំណើនយឺតៗជាណើរៗ ដើម្បីងើបផុតពីវិបត្តិកូវីដ១៩។ គួររំលឹកថា កាលពីឆ្នាំ២០២០ កូវីដ១៩រីករាលដាលយ៉ាងខ្លាំង និងបានបណ្តាលឱ្យឧស្សាហកម្មនៅជុំវិញពិភពលោកត្រូវបានបិទ។ ខណៈពេលដែលមនុស្សភាគច្រើនត្រូវស្ថិតនៅក្នុងតំបន់បិទខ្ទប់ ដែលជាហេតុនាំឱ្យតម្រូវការរបស់អ្នកប្រើប្រាស់មានការថយចុះ។ ទន្ទឹមនឹងនេះសកម្មភាពឧស្សាហកម្មក៏ធ្លាក់ចុះដែរ។

ប៉ុន្តែបន្ទាប់ពីការបើកខ្ទប់ថមថយ ឬមានការស្រាកស្រាន្តធ្វើឱ្យតម្រូវការមានការកើនឡើង ខណៈដែលសង្វាក់ផលិតកម្ម ដែលបានទទួលរងផលប៉ះពាល់ដោយសារកូវីដ១៩ នៅតែប្រឈមនឹងបញ្ហារាំរៃពិបាកត្រលប់មករកភាពប្រក្រតីវិញ។ បញ្ហានេះបានបណ្តាលឱ្យមានភាពច្របូកច្របល់ របស់រោងចក្រ និងការចែកចាយទំនិញ ព្រោះរោងចក្រមួយចំនួនមិនអាចផលិត

និងផ្គត់ផ្គង់ច្រើនដូចមុនពេលមានកូវីដដូចជា៖ ការផ្គត់ផ្គង់សាច់ ថ្នាំពេទ្យ និងសម្ភារៈបរិក្ខាប្រើប្រាស់នៅក្នុងផ្ទះជាដើម។

ឧបសគ្គនៅក្នុងសង្វាក់ផលិតកម្ម និងការផ្គត់ផ្គង់កើតមានឡើងដោយសារតែខ្វះកម្លាំងពលកម្ម វត្ថុធាតុដើម និងសមាសធាតុសំខាន់ៗដូចជា៖ នៅប្រទេសចិនជួបប្រទះនឹងបញ្ហាកង្វះថាមពល ខណៈបញ្ហា Brexit ធ្វើឱ្យអង់គ្លេសខ្វះខាតអ្នកបើកបររថយន្តដឹកទំនិញ។ល។

កត្តាទាំងនេះបានធ្វើឱ្យអ្នកវិភាគយល់ឃើញថា សង្វាក់ផលិតកម្មនឹងត្រូវប្រឈមនឹងបញ្ហាធ្ងន់ធ្ងរមួយចំនួនមុននឹងត្រលប់មករកភាពល្អប្រសើរឡើងវិញ ។ បញ្ហានេះបានធ្វើឱ្យកំណើនសេដ្ឋកិច្ចនៅចិន និងអឺរ៉ុបជួបមានឧបសគ្គមួយចំនួន។ ប៉ុន្តែទោះយ៉ាងណាការព្យាករណ៍បានបង្ហាញថា វិស័យផលិតកម្មប្រហែលជានឹងអាចវិលត្រលប់មករកភាពប្រក្រតីវិញនៅក្នុងត្រីមាសទី២ ឆ្នាំ ២០២២ ខាងមុខ៕ *ដោយ វង្ស ច័ន្ទស្មើដារា*

*ប្រភព៖ គេហទំព័រ CNBC ចេញផ្សាយថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២១*

## IMF៖ កំណើនអតិផរណា និងភាពមិនប្រាកដប្រជាកូវីដ១៩ កំពុងគំរាមកំហែងដល់ការស្តារសេដ្ឋកិច្ចសកល



*ដោយ ខេមបូណ្ឌមីស*

ការគំរាមកំហែងដល់ការស្ទុះងើបឡើងវិញនៃសេដ្ឋកិច្ចពិភពលោក គឺបង្កឡើងដោយការរីករាលដាលនៃមេរោគកូវីដ១៩នៅតែបន្ត និងបញ្ហាអត្រាអតិផរណាកំពុងមានការកើនឡើងខ្ពស់។

ស្ថាប័នមូលនិធិរូបិយវត្ថុអន្តរជាតិ(IMF)បានអំពាវនាវឱ្យមានកិច្ចខិតខំប្រឹងប្រែងឱ្យបានច្រើន ពីប្រទេសអ្នកមាន សម្រាប់ជំរុញអត្រាចាក់វ៉ាក់សាំងបង្ការកូវីដ១៩ នៅក្នុងប្រទេសក្រីក្រ សម្រេចឱ្យបានដល់៤០%នៃពលរដ្ឋសរុប នៅមុនដំណាច់ឆ្នាំនេះ និងឈានដល់៧០%ត្រឹមពាក់កណ្តាលឆ្នាំក្រោយ។ ជាមធ្យមមានពលរដ្ឋ៦០% ក្នុងប្រទេសអ្នកមានទាំងអស់ក្នុងពិភពលោក បានទទួលការចាក់វ៉ាក់សាំងកូវីដ១៩ ខណៈមានតែ៤%ប៉ុណ្ណោះ នៃពលរដ្ឋប្រទេសក្រីក្រ ដែលទទួលបានការចាក់វ៉ាក់សាំង។

ជាមួយគ្នានេះ IMF ក៏បានស្នើឱ្យធនាគារកណ្តាលនៃបណ្តាប្រទេសទាំងអស់ចាត់វិធានការឱ្យបានឆាប់រហ័សតាមលទ្ធភាពប្រទេសរៀងៗខ្លួន ដើម្បីឆ្លើយតបឱ្យទាន់ពេលវេលា នូវអត្រាអតិផរណាដែលពុំសូវមានស្ថិរភាព។ ជាក់ស្តែង អត្រាអតិផរណានៃទំនិញបោះដុំនៅសហរដ្ឋអាមេរិក បានកើនឡើងជិត៩% នៅក្នុងខែកញ្ញាឆ្នាំនេះ បើប្រៀបធៀបទៅនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន ហើយអតិផរណាទំនិញលក់រាយវិញបានកើន០,៤%។

IMF បានទម្លាក់ការព្យាករសេដ្ឋកិច្ចពិភពលោកក្នុងឆ្នាំ២០២១ ពី៦% មកនៅត្រឹម ៥,៩%វិញ។ ឥទ្ធិពលនៃជំងឺរាតត្បាតកូវីដ១៩ កាន់តែអាក្រក់ទៅៗ បានធ្វើឱ្យសេដ្ឋកិច្ចនៃប្រទេសដែលមានប្រាក់ចំណូលទាប បានខិតទៅរកភាពលិចលង់ ប្រទេសអ្នកមានក៏កំពុងជួបការលំបាកក្នុងខ្សែសង្វាក់ផ្គត់ផ្គង់៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព៖ខេមបូណ្ឌមីស ចេញផ្សាយថ្ងៃទី១៦ ខែតុលា ឆ្នាំ២០២១។*

## ទិន្នន័យស្រាវជ្រាវសម្រាប់សប្តាហ៍បន្ទាប់

ថ្ងៃចន្ទ ទី២៥ ខែតុលា ឆ្នាំ២០២១

- កំណើននៃការលក់ដុំនៅក្នុងប្រទេសកាណាដា នៅក្នុងខែសីហា ឆ្នាំ ២០២១
- ការធ្លាក់ចុះអត្រានីកម្មភាព របស់ម៉ិកស៊ិក ក្នុង ខែសីហាឆ្នាំ ២០២១

ថ្ងៃអង្គារ ទី២៦ ខែតុលា ឆ្នាំ២០២១

- ឱនភាពថវិកា សហរដ្ឋអាមេរិក នៅខែសីហាឆ្នាំ ២០២១ បើប្រៀបធៀប ក្នុងរយៈពេលដូចគ្នា កាលពីឆ្នាំមុន
- កំណើនសេដ្ឋកិច្ចរបស់ប្រទេសកូរ៉េខាងត្បូង បានកើនឡើង ៦% នៅក្នុងត្រីមាសទី ២ នៃឆ្នាំ ២០២១

ថ្ងៃពុធ ទី២៧ ខែតុលា ឆ្នាំ២០២១

- កំណើនអត្រាអតិផរណាប្រចាំឆ្នាំនៅអូស្ត្រាលី បានកើនឡើងដល់ ៣,៨% នៅក្នុងត្រីមាសទី ២ ឆ្នាំ ២០២១ ពី ១,១% នៅក្នុងត្រីមាសទី ១
- ឱនភាពពាណិជ្ជកម្មរបស់ប្រទេសម៉ិកស៊ិក នៅ ខែសីហាឆ្នាំ ២០២១

ថ្ងៃព្រហស្បតិ៍ ទី២៨ ខែតុលា ឆ្នាំ២០២១

- សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់នៅអាល្លឺម៉ង់បាន ធ្លាក់ចុះ នៅខែកញ្ញាឆ្នាំ ២០២១ ធៀបខែមុន
- ឱនភាពពាណិជ្ជកម្មម៉ិកស៊ិក នៅខែសីហាឆ្នាំ ២០២១

ថ្ងៃសុក្រ ទី២៩ ខែតុលា ឆ្នាំ២០២១

- កំណើនសន្ទស្សន៍ទំនុកចិត្តអ្នកប្រើប្រាស់នៅ ជប៉ុន ក្នុងខែកញ្ញាឆ្នាំ ២០២១
- កំណើនផលិតផលក្នុងស្រុកសរុប (GDP) នៅ អេស្ប៉ាញ នៅត្រីមាសទី ២ នៃឆ្នាំ ២០២១៕